ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ២៣៤
ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២
សាលដីកា
លេខ : ១៧៣ "ជ"
ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤

# សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាសវនាការជាសាធារណៈនៅថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០១៤។

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

### ក្រឡាបញ្ជី

លោកស្រី [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

ដើមចោទៈអ្នកស្រី [redacted] ធិចជូ (ចុងបណ្តឹងសាទុក្ខ) អាយុ ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃក្រុមទី ០១ ភូមិថ្មគោល ឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង។

មេធាវី : លោក [redacted] តំណាងដោយអាណត្តិ

ចុងចម្លើយៈលោក [redacted] ប៊ិន (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៦៦ឆ្នាំ ជាតិខ្មែរ និង ប្រពន្ធឈ្មោះ [redacted] នី អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ក្រុមទី ១១ ភូមិប្រគាប ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

Scanned with CamScanner

មេធាវី : លោកស្រី [redacted] តំណាងដោយអាណត្តិ

អំពីវិវាទៈ-ប្តឹងទាមទារប្រាក់ និង សុំអោយរុះរើចេញពីដី

## អំពីអង្គហេតុនិង ចំណុចវិវាទៈ

ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារៈ

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១ របស់ដើមចោទបានអោយដឹងថា : កាលពីថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ ២០០៧ ឈ្មោះ [redacted]ប៊ិន និង ប្រពន្ធឈ្មោះ [redacted]ទី បានលក់ផ្តាច់នូវដី និង ផ្ទះមួយកន្លែងមានទំហំ ៦២០ម៉ែត្រក្រឡា មានបណ្តោយ ៥៧,៣ម ទទឹងខាងត្បូង ១០,៤០ម នឹង ទទឹងខាងជើង ១១,២៥ម ស្ថិតនៅភូមិប្រគាប ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង និង បានទំនាក់ទំនងខ្ចីចងការប្រាក់ពីដើមចោទចំនួន ៩.៣៩៥ដុល្លាអាមេរិក ក្រោយពេលលក់ដី និង ផ្ទះអោយដើមចោទរួចហើយ ចុងចម្លើយមិនព្រមចេញពីដីនោះទេ ថែមទាំងមិនព្រមសងប្រាក់ដែលជំពាក់ដើមចោទទៀត ហើយបានគេចវេសមិនព្រមមកជួបដល់សព្វថ្ងៃ ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៤(ខ) ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង សំរេចៈ**

១-ក/ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១ របស់ដើមចោទឈ្មោះ [redacted] ធិចជូ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ។

ខ/ទទួលពាក្យបណ្តឹងតប ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១១ របស់ឈ្មោះ[redacted] ទី និង ឈ្មោះ [redacted] ប៊ិន ធ្វើឡើងត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតលក់ផ្តាច់អចលនវត្ថុ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧, កិច្ចសន្យាខ្ចីប្រាក់បញ្ចាំទ្រព្យ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧ និង លិខិតបញ្ជាក់ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-បង្គាប់អោយចុងចម្លើយឈ្មោះ[redacted] ទី និង ឈ្មោះ [redacted] ប៊ិន ប្រគល់ដី និង ផ្ទះដែលមានទំហំ ៦២០ ម៉ែត្រក្រឡា ស្ថិតនៅភូមិប្រគាប ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង អោយទៅឈ្មោះ[redacted]ធិចជូ ជាដើមបណ្តឹង ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៤-បង្គាប់អោយចុងចម្លើយឈ្មោះ[redacted] ទី និង ឈ្មោះ [redacted] ប៊ិន រួមគ្នាសងប្រាក់ចំនួន ៩.៣៩៥ដុល្លាអាមេរិក( ប្រាំបួនពាន់បីរយកៅសិបប្រាំដុល្លាអាមេរិក) ទៅដើមចោទឈ្មោះ[redacted]ធិចជូ ចាប់ពីពេលសាលក្រមចូលជាស្ថាពរ ការទាមទារលើសពីនេះបដិសេធចោល ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។



Scanned with CamScanner

*សាលក្រមនេះត្រូវបានឈ្មោះ [redacted] ប៊ិន និង ឈ្មោះ [redacted] នី ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ២៤៧ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ត្រង់ចំណុចទាំងមូល នៃសេចក្តីសំរេច ។*

---

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៨ "ក្រ ៧ ញ" ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ របស់សាលា

ឧទ្ធរណ៍ សំរេច ៖

១-ប្រានបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ឈ្មោះ ពេជ ប៊ិន និង សែ នី ចោលជាអសារបង់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២៤ "ខ" ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

៤-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ ទុកសិទ្ធិអោយប្តឹងសាទុក្ខរយៈពេលមួយខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

*សាលដីកានេះត្រូវបានឈ្មោះ [redacted] ប៊ិន ប្តឹងសាទុក្ខតាមបណ្តឹងលេខ ២២២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។*

ខ-<u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u> ៖

ឈ្មោះ [redacted] ប៊ិន ធ្វើសេចក្តីថ្លែងការណ៍ថា ៖ ក្នុងឆ្នាំ ១៩៩៩ រហូតឆ្នាំ ២០០៧ ខ្លួនបានខ្ចីចងការប្រាក់ពីឈ្មោះ [redacted] សែ ៨០ម៉ឺនបាត និង ១០.០០០ដុល្លាជាង ក្រោយមកបានសងប្រាក់ដើម និង ការប្រាក់រួចអស់ហើយ ដោយកាត់ត្រាក់ទ័រ និង ម៉ាស៊ីនបោកស្រូវអោយ តែសងពុំចេះរួចសោះ ព្រោះការប្រាក់នៅសល់គាត់កាត់ជាប្រាក់ដើមវិញ និង កើតជាការតទៅទៀត ។

ចំពោះដី ៥០ហិកតា ខ្លួនមិនបានលក់អោយគាត់ទេ ។

មានកិច្ចសន្យា ៣ ដែលធ្វើក្នុងថ្ងៃតែមួយ គឺ ថ្ងៃទី ៣០-០៥-២០០៧ ៖

១-កិច្ចសន្យាខ្ចីប្រាក់ ៩.៣៩៥ដុល្លា តែគ្មានសាច់ប្រាក់ទេ

២-កិច្ចសន្យាលក់ផ្តាច់ដី និង ផ្ទះ

៣-កិច្ចសន្យាទិញផ្ទះ និង ដីយកវិញក្នុងរយៈពេល ៣ឆ្នាំ តម្លៃ ១៣.០០០ដុល្លា

សំណូមពរ ៖ សុំសងប្រាក់ ៥.០០០ដុល្លា និង សុំទាមទារដីផ្ទះ និង ដីស្រែយកវិញ ព្រោះខ្លួនខ្ចីចងការប្រាក់ ១០.០០០ដុល្លា តែទទួលបានតែ ៥.០០០ដុល្លា ប៉ុណ្ណោះ ដោយគាត់កាត់ការប្រាក់ដែលនៅជំពាក់ ។



Scanned with CamScanner

ឈ្មោះ [redacted] ផិចជូ ធ្វើសេចក្តីថ្លែងការណ៍ថា ៖ កិច្ចសន្យាទាំងអស់គឺកើតឡើងពីការព្រមព្រៀងគ្នានៅចំពោះមុខមេភូមិ ។ ចំពោះកិច្ចសន្យាទិញវិញលើសពី ៣ឆ្នាំ គឺមេឃុំធ្វើអោយទាំងអស់ ដូច្នេះ ការលើកឡើងរបស់ចុងចម្លើយ គឺមិនត្រឹមត្រូវទេ សុំបដិសេធ ។ ដីស្រែដែលគាត់យកមកលក់អោយខ្លួនៗមិនស្គាល់ស្រែទេ គឺគាត់ជាអ្នកមកអង្វរអោយខ្លួនទិញ ។ ចំពោះកិច្ចសន្យាលក់ផ្ទះ គឺគាត់សុំលុយនៅ ៥.០០០ដុល្លា និង សងប្រាក់ដែលនៅជំពាក់ខ្លួន ៥.០០០ដុល្លា ទើបនៅសល់ប្រាក់ជំពាក់ ៩.៣៩៥ដុល្លាអាមេរិកទៀត ។

លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថា៖ វិវាទនេះកើតចេញពីកិច្ចសន្យាខ្ចីប្រាក់ដាក់បញ្ចាំអចលនវត្ថុ រវាងដើមចោទ និង ចុងចម្លើយ ។ ដើមចោទបានយកការប្រាក់ធ្វើជាប្រាក់ដើម និង គិតការលើប្រាក់ការតទៅទៀត ទើបកូនក្តីខ្លួនសងមិនចេះអស់សោះ ។

ពេលកូនក្តីខ្លួនត្រូវការប្រាក់ ១០.០០០ដុល្លា ក៏បានទៅខ្ចីដើមចោទទៀត ទើបក្នុងមួយថ្ងៃធ្វើកិច្ចសន្យាដល់ទៅបី ។ ការប្រាក់ដែលកូនក្តីខ្លួនបានសង គឺលើសច្បាប់កំណត់ច្រើនលើសលុប ទើបកូនក្តីខ្លួនសងមិនចេះរួចសោះ ។

សំណូមពរ ៖ សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា៖ការលើកឡើងរបស់កូនបំណុល គ្រាន់តែជាការដោះបន្ទុកដើម្បីគេចវេសពីបំណុល ដែលពុំមានភស្តុតាងជាឯកសារផ្លូវច្បាប់បញ្ជាក់ទេ ។

ពុំមានឯកសារកាត់កងដីស្រែទេ មានតែលិខិតទិញលក់ប៉ុណ្ណោះ នៅថ្ងៃទី ៣០-០៥-២០០៧ គឺគូភាគីបានសុំអោយលោកមេឃុំធ្វើលិខិត ៖

១-លក់ផ្តាច់អចលនវត្ថុតម្លៃ ១០.០០០ដុល្លា ដោយគាត់កាត់ប្រាក់ជំពាក់មុន ៥.០០០ដុល្លា នៅសល់ប្រាក់ជំពាក់៩.៣៩៥ដុល្លាទៀត ហើយមូលហេតុមិនកាត់ទាំងអស់ ព្រោះចុងចម្លើយសុំថា យកទៅដោះដូរដីធ្លី ។

២-លិខិតជំពាក់ប្រាក់ ៩.៣៩៥ដុល្លាអាមេរិក

៣-លិខិតបញ្ជាក់សុំលោះដីវិញក្នុងតម្លៃ ១៣.០០០ដុល្លាអាមេរិក ក្នុងរយៈពេល ៣ឆ្នាំ ។

ចុងចម្លើយពុំមានលិខិតបញ្ជាក់ពីការខ្ចីចងការប្រាក់ទេ ។ ចុងចម្លើយមានចេតនាទុច្ចរិតម្តងហើយ ម្តងទៀត ដូចជាបដិសេធស្នាមមេដៃរបស់ខ្លួនលើកិច្ចសន្យា ឯកូនក្តីខ្លួន នៅសាលាដំបូងគាត់សុខចិត្តលះបង់ប្រាក់ជំពាក់ ៩.៣៩៥ដុល្លាចោលទៀត តែនៅពេលសវនាការតុលាការកំពូលនេះ កូនក្តីខ្លួនសុំទាមទារប្រាក់នេះវិញគ្រប់ចំនួន ។

សំណូមពរ ៖ សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។



Scanned with CamScanner

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់គូភាគី និង មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២២២ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ របស់ចុងចម្លើយឈ្មោះ [redacted] ប៊ិន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចទទួលស្គាល់ការទាមទាររបស់ដើមចោទដោយសំអាងលើភស្តុតាងនានាដូចជា លិខិតលក់ផ្ដាច់អចលនវត្ថុ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧, កិច្ចសន្យាខ្ចីប្រាក់បញ្ចាំទ្រព្យ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧ និង លិខិតបញ្ជាក់ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧ ថា កំណត់បាននូវអង្គហេតុ នៃការទិញលក់ផ្ទះទំនាស់រវាងដើមចោទ និង ចុងចម្លើយក្នុងតម្លៃ ១០.០០០(មួយម៉ឺន)ដុល្លា និង អង្គហេតុខ្ចីប្រាក់ចំនួន ៩.៣៩៥( ប្រាំបួនពាន់ បីរយ កៅសិបប្រាំ)ដុល្លា នោះ ពុំទាន់បានពិចារណាអោយបានគ្រប់គ្រាន់នៅឡើយទេ ព្រោះថា លិខិតបីច្បាប់ដែលដើមចោទជូនមកតុលាការ ត្រូវបានបង្កើតឡើងនៅថ្ងៃ ខែ ឆ្នាំ តែមួយ និង បើមានអង្គហេតុ នៃការទិញលក់ផ្ទះតាមលិខិតលក់ផ្ដាច់ និង លិខិតបញ្ជាក់ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧ មែននោះ មូលហេតុអ្វីបានជាគូភាគីបង្កើតលិខិតជាកិច្ចសន្យាខ្ចីប្រាក់បញ្ចាំទ្រព្យ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៧ ផង ព្រមទាំងបង្កើតលិខិតជួលដី និង ផ្ទះ គ្មានកាលបរិច្ឆេទ គ្មានខ្លឹមសារច្បាស់លាស់ តែមានស្នាមម្រាមដៃអ្នកជួលឈ្មោះ [redacted] ប៊ិន ជាចុងចម្លើយ និង ឈ្មោះ [redacted] ធិចជូ ជាដើមចោទទៀតផង ។ ករណីនេះ សកម្មភាពរបស់គូភាគីក្នុងភាពមិនច្បាស់លាស់នៅឡើយ ។ ដូច្នេះ គប្បីអនុវត្តតាមស្មារតីមាត្រា ២៣ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច កំណត់ថា ក្នុងករណីសង្ស័យ កិច្ចសន្យាត្រូវបានបកស្រាយជាប្រយោជន៍នៃភាគីកូនបំណុល ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤៨ ក្រ.ប.ញ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចមកនេះ មិនទាន់មានលក្ខណៈត្រឹមត្រូវទេ ។

## ហេតុដូច្នេះ

## វិ និ ច្ឆ័ យ សេ ច ក្ដី

១-ទទួលបណ្ដឹងសាទុក្ខលេខ ២២២ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ របស់ចុងចម្លើយឈ្មោះ [redacted] ប៊ិន ។

Scanned with CamScanner

២-បដិសេធសាលដីកាវដ្ឋប្បវេណីលេខ ៤៨ ក្រvញ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៣៤ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះសាជាថ្មី។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ដើមចោទ។

៥-សាលដីកានេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៤។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤

ប្រធាន

[redacted]